ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ការគាំទ្រដល់រដ្ឋបាលឃុំ សង្កាត់

ថ្ងៃចន្ទ ១០រោច ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ត្រូវនឹងថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៦

# មាតិកា

១ ទិដ្ឋភាពទូទៅនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

២ រដ្ឋបាលឃុំ សង្កាត់

៣ ប្រាក់សោធននិវត្តន៍ និងផលប្រយោជន៍ផ្សេងៗសម្រាប់ឃុំ សង្កាត់

# ១. ទិដ្ឋភាពទូទៅនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

| ចំណូល ចំណាយ | ២០២៥ | ២០២៦ | | | |
|---|---|---|---|---|---|
| | លរ.រ | លរ.រ | លរ.$ | កំណើន% | ចំណែកជា% |
| **ចំណូលសរុប** | **7,193,664.00** | 7,069,724.00 | 1,752.10 | -1.7% | 100.0% |
| ចំណូលចរន្ត | **7,193,664.00** | **7,069,724.00** | 1,752.10 | **-1.7%** | **100.0%** |
| ចំណូលសារពើពន្ធ | 2,218,739.00 | 1,987,570.00 | 492.58 | -10.4% | 28.1% |
| ចំណូលមិនមែនសារពើពន្ធ | 300,735.00 | 417,014.00 | 103.35 | 38.7% | 5.9% |
| ចំណូលផ្សេងៗ | 4,674,190.00 | 4,665,140.00 | 1,156.17 | -0.2% | 66.0% |
| ឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | 4,641,454.00 | 4,609,237.70 | 1,142.31 | -0.7% | 99% |
| មូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | 32,736.00 | 55,902.30 | 13.85 | 70.8% | 1% |
| **ចំណាយសរុប** | **7,193,664.00** | **7,069,724.00** | 1,752.10 | **-1.7%** | **100%** |
| ចំណាយចរន្ត | 6,793,664.00 | 6,685,724.00 | 1,656.93 | -1.6% | 94.6% |
| ចំណាយបន្ទុកបុគ្គលិក | 3,247,988.00 | 3,272,658.50 | 811.07 | 0.8% | 48.9% |
| ចំណាយមិនមែនបន្ទុកបុគ្គលិក | 3,545,676.00 | 3,413,065.50 | 845.87 | -3.7% | 51.1% |
| ចំណាយមូលធន | 400,000.00 | 384,000.00 | 95.17 | -4.0% | 5.4% |

**ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០២៦**

ចំណូលសរុប ៧ ០៦៩ ៧២៤,០០ លរ.រ

ចំណាយសរុប ៧ ០៦៩ ៧២៤,០០ លរ.រ

# ២.ថវិការដ្ឋបាលឃុំ សង្កាត់

អនុក្រឹត្យ ១៥៣ អនក្រ.បក

ចុះថ្ងៃទី១០ កក្កដា ឆ្នាំ២០២៣

➢ រដ្ឋបាលឃុំ សង្កាត់ ត្រូវរៀបគម្រោងចំណូលផ្នែកលើ៖

(១). មូលនិធិឃុំ សង្កាត់ ទទួលបាន ៣.៥% នៃចំណូលចរន្ត ថវិកាថ្នាក់ជាតិ និងចំណូលសេវា

- ៦៤
- រដ្ឋបាល: 17% X (CS-64)
- 69: 5% X (CS-64)
- សេវាសង្គម និងអនាម័យបរិស្ថាន: 22% X (CS-64)
- អភិវឌ្ឍន៍: 17% X (CS-64)

**ចំណាយសម្រាប់ប្រតិបត្តិការរដ្ឋបាល៖**

ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សា និងមេភូមិ

ចំណាយកិច្ចការរដ្ឋបាលផ្សេងៗទៀត៖

រូបមន្តផ្អែកលើ៖

- ចំណែកស្មើគ្នា = ៤០%
- ចំនួនក្រុមប្រឹក្សា = ៦០%

**ចំណាយសមាសភាគសេវាសង្គម និងបរិស្ថាន៖**

- ចំណែកស្មើគ្នា = ៣០%
- ចំនួនប្រជាពលរដ្ឋ = ២០%
- សន្ទស្សន៍ភាពក្រីក្រ=៥០%

**ចំណាយសមាសភាគអភិវឌ្ឍមូលដ្ឋាន៖**

- ចំណែកស្មើគ្នា = ៣០%
- ចំនួនប្រជាពលរដ្ឋ = ៣០%
- សន្ទស្សន៍ភាពក្រីក្រ=៣០%
- ចំនួនភូមិ = ១០%

# ២.ថវិការដ្ឋបាលឃុំ សង្កាត់

- **រដ្ឋបាលឃុំ សង្កាត់ ត្រូវរៀបគម្រោងចំណូលផ្អែកលើ៖**

(២). ថវិកាបន្ថែម សម្រាប់អភិវឌ្ឍន៍មូលដ្ឋាន ក្នុងអត្រា **១%** នៃចំណូលចរន្តថវិកាថ្នាក់ជាតិ

(៣). ចំណូលពីចំណូលសារពើពន្ធ របស់រដ្ឋបាលរាជធានី ខេត្ត ក្នុងអត្រា ៦%

**(លើកលែងសង្កាត់ក្នុងរាជធានី)**

**ចំណាយសមាសភាគអភិវឌ្ឍមូលដ្ឋាន៖**

- ចំណែកស្មើគ្នា = ៣០%
- ចំនួនប្រជាពលរដ្ឋ = ៣០%
- សន្ទស្សន៍ភាពក្រីក្រ=៣០%
- ចំនួនភូមិ = ១០%

# ២.ថវិការដ្ឋបាលឃុំ សង្កាត់

| ឆ្នាំ | មូលនិធិ | ចំណូលចែករំលែក | ធនធានបន្ថែម១% |
|---|---|---|---|
| 2002 | ៣០ ប៊ីល.រ | | |
| 2003 | 2% | | |
| 2004 | 2.50% | | |
| 2005 | 2.52% | | |
| 2006 | 2.54% | | |
| 2007 | 2.56% | | |
| 2008 | 2.70% | | |
| 2009 | 2.75% | | |
| 2010 To 2018 | 2.80% | 1.00% | |
| 2019 | 3% | 1.00% | |
| 2020 | 3.10% | 4.00% | 1% |
| 2021 | 3.20% | 4.50% | 1% |
| 2022 | 3.30% | 5.00% | 1% |
| 2023 | 3.40% | 5.50% | 1% |
| 2024 To 2028 | 3.50% | 6.00% | 1% |

**ការផ្ទេរធនធាន៖**

- ត្រីមាសទី១ = ២៥%
- ត្រីមាសទី២ = ២៥%
- ត្រីមាសទី៣ = ៤០%
- ត្រីមាសទី៤ = ១០%

**ការផ្ទេរធនធាន៖**

- ត្រីមាសទី១ = ២៥%
- ត្រីមាសទី២ = ២៥%
- ត្រីមាសទី៣ = ២៥%
- ត្រីមាសទី៤ = ២៥%

# ៣. ប្រាក់សោធនិវត្តន៍ និងផលប្រយោជន៍ផ្សេងៗសម្រាប់ឃុំ សង្កាត់

១. ប្រាក់លំហែមាតុភាព

២. កម្មវិធីសាច់ប្រាក់ឧបត្ថម្ភ

៣. គោលនយោបាយរបបសន្តិសុខសង្គម

៤. ការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែ

៥. ការសិក្សាលើការផ្តល់ប្រាក់សោធននិវត្តន៍

# ៣.១.ផ្តល់ប្រាក់លំហែមាតុភាព

- អនុវត្តចាប់ពីឆ្នាំ ២០២៦
- សម្រាប់ក្រុមប្រឹក្សាជាស្ត្រី របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ថវិកាគ្រោងក្នុងរដ្ឋបាលសាមី (៨០០,០០០រៀល/បុត្រ ១)

ឧទាហរណ៍៖ កូនភ្លោះពីរទទួលបាន ១ ២០០ ០០០ រៀល, កូនភ្លោះបី ទទួលបាន ១ ៦០០ ០០០ រៀល។

# ៣.២. ការអនុវត្តកម្មវិធីផ្តល់សាច់ប្រាក់ឧបត្ថម្ភ

- ចាប់ពីឆ្នាំ ២០២៦, រាជរដ្ឋាភិបាល ពង្រីកវិសាលភាពនៃការអនុវត្តកម្មវិធីផ្តល់សាច់ប្រាក់ឧបត្ថម្ភ សម្រាប់ក្រុមប្រឹក្សា របស់រដ្ឋបាលថ្នាក់ក្រោមជាតិមានបណ្តប.ស.ស ជាស្ត្រីមានផ្ទៃពោះ និងកុមារក្រោមអាយុ ២ឆ្នាំ។
- ពិនិត្យផ្ទៃពោះ ៨០ ០០០ រៀល ក្នុង១ដង (៤ដង)
- ពិនិត្យសុខភាពក្រោយសម្រាល ៨០ ០០០ រៀល ក្នុង១ដង (១០ដង ក្នុងនោះ ៣ដងសម្រាប់ម្តាយពិនិត្យសុខភាព ៧ដងសម្រាប់កុមារមកទទួលថ្នាំបង្ការ)
- ពេលសម្រាល៖ ៨០០ ០០០រៀល (រដ្ឋបាលសាមី)

សរុបថវិកា ចាប់ពីមានផ្ទៃពោះ រហូតដល់បុត្រអាយុ២ឆ្នាំ
រដ្ឋឧបត្ថម្ភថវិកាសរុប ១ ៩២០ ០០០ រៀល

# ៣.៣.គោលនយោបាយរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងថែទាំសុខភាព

- អនុក្រឹត្យលេខ៦២ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤, រាជរដ្ឋាភិបាល បានពង្រីកវិសាលភាពគោលនយោបាយ របបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងថែទាំសុខភាព ដល់ក្រុមប្រឹក្សារាជធានី/ខេត្ត, ក្រុមប្រឹក្សាក្រុង/ស្រុក/ខណ្ឌ, និងក្រុមប្រឹក្សាឃុំ/សង្កាត់ ព្រមទាំង មន្ត្រីភូមិទូទាំងប្រទេស (ប័ណ្ណ ប.ស.ស) **ដោយរដ្ឋជាអ្នករ៉ាប់រងលើសេវាថែទាំសុខភាព។**

# ៣.៤. ការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែ

➢ រាជរដ្ឋាភិបាល គ្រោងដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែ ដល់សមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ទាំង៣ថ្នាក់ ជាបន្តបន្ទាប់, ដាក់ស្តែងនៅឆ្នាំ២០២៧ គ្រោងដំឡើង ដូចខាងក្រោម៖

| បរិយាយ | ចំនួន (នាក់) | ប្រាក់ឧបត្ថម្ភប្រចាំខែឆ្នាំ២០២៦ | គ្រោងដំឡើង | ប្រាក់ឧបត្ថម្ភប្រចាំខែឆ្នាំ២០២៧ |
|---|---|---|---|---|
| ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត | 25 | 1,685,000 | 50,000 | 1,735,000 |
| សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត | 534 | 1,280,000 | 30,000 | 1,310,000 |
| សរុប | 559 | | | |
| ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | 210 | 1,395,000 | 50,000 | 1,445,000 |
| សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | 3,444 | 1,050,000 | 30,000 | 1,080,000 |
| សរុប | 3,654 | | | |
| មេឃុំ ចៅសង្កាត់ | 1,652 | 1,345,000 | 50,000 | 1,395,000 |
| ជំទប់ទី១/ទី២, ចៅសង្កាត់រងទី១/ទី២ | 3,304 | 1,005,000 | 30,000 | 1,035,000 |
| សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | 6,666 | 895,000 | 30,000 | 925,000 |
| សរុប | 11,622 | | | |

# ៣.៤. ការតំឡើងប្រាក់ឧបត្ថម្ភប្រចាំខែ(ត)

➢ រាជរដ្ឋាភិបាល គ្រោងដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែដល់មេភូមិ, អនុប្រធានភូមិ និងជំនួយការភូមិ ដោយយកប្រាក់ឧបត្ថម្ភប្រចាំខែ មន្ត្រីជាប់កិច្ចសន្យាមុខងារសាធារណៈ ជាគោល។ ការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែ គ្រោងធ្វើឡើងរៀងរាល់ឆ្នាំ (៥ឆ្នាំ) ចាប់ពីឆ្នាំ ២០២៧ ដល់ឆ្នាំ ២០៣១។

| បរិយាយ | បច្ចុប្បន្ន ២០២៦ | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | | ២០៣១ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ដំឡើង | សរុបប្រចាំខែ | ដំឡើង | សរុបប្រចាំខែ | ដំឡើង | សរុបប្រចាំខែ | ដំឡើង | សរុបប្រចាំខែ | ដំឡើង | សរុបប្រចាំខែ |
| មេភូមិ | 570,000 | 60,000 | 630,000 | 60,000 | 690,000 | 60,000 | 750,000 | 60,000 | 810,000 | 80,000 | 890,000 |
| អនុប្រធានភូមិ | 445,000 | 60,000 | 505,000 | 60,000 | 565,000 | 60,000 | 625,000 | 60,000 | 685,000 | 80,000 | 765,000 |
| សមាជិកភូមិ | 415,000 | 60,000 | 475,000 | 60,000 | 535,000 | 60,000 | 595,000 | 60,000 | 655,000 | 80,000 | 735,000 |
| មន្ត្រីជាប់កិច្ចសន្យា | 790,000 | 20,000 | 810,000 | 20,000 | 830,000 | 20,000 | 850,000 | 20,000 | 870,000 | 20,000 | 890,000 |

# ៣.៥.ការសិក្សាលើការផ្តល់ប្រាក់សោធននិវត្តន៍

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម (អ.ក.គ.)

- សិក្សាពីម៉ូឌែលសម្រាប់ផ្តល់ប្រាក់សោធន ជូនក្រុមប្រឹក្សា នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាប់ឆ្នោត លើសពី៣អាណត្តិឡើង។
- បានសុំទិន្នន័យសមាជិកក្រុមប្រឹក្សា ពីក្រសួងមហាផ្ទៃ, គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងបេឡាជាតិសន្តិសុខសង្គម កាលពីខែធ្នូ ឆ្នាំ ២០២៥ កន្លងទៅ **ដើម្បីសិក្សាលើទិដ្ឋភាពថវិកា និងព្យាករណ៍បន្ទុកចំណាយជាក់លាក់ ដើម្បីបន្តសម្របសម្រួល រៀបចំយន្តការអនុវត្តការងារនេះ** សំដៅលើកសំណើជាជម្រើស សម្រាប់យន្តការអនុវត្ត ក្នុងការផ្តល់ប្រាក់សោធនសម្រាប់សមាជិកក្រុមប្រឹក្សា នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានជាប់ឆ្នោតលើសពី៣ អាណត្តិឡើង។

# ៣.៥.ការសិក្សាលើការផ្តល់ប្រាក់សោធននិវត្តន៍(ត)

- ទិន្នន័យដែលទទួលបានពីក្រសួង-ស្ថាប័ន ពាក់ព័ន្ធ, ក្នុងនោះក្រសួងមហាផ្ទៃ មានព័ត៌មានអាចប្រើសម្រាប់ការសិក្សា និងជាមូលដ្ឋានអនុវត្តការផ្តល់ប្រាក់សោធន ជូនសមាជិកក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានជាប់ឆ្នោតលើសពី៣ អាណត្តិ។ បច្ចុប្បន្ន, ក្រសួងមហាផ្ទៃ បានផ្តល់ទិន្នន័យ ចំនួន ២ខេត្ត (ខេត្តបាត់ដំបង និងប៉ៃលិន)។
- ដំណើរការសិក្សា ផ្អែកទិន្នន័យបឋមរបស់ក្រុមប្រឹក្សា មានដូចជា៖ អាយុ, កម្រិតប្រាក់ឧបត្ថម្ភ, និងកាលបរិច្ឆេទចូលបម្រើការងារដោដើម,
- ទិន្នន័យបឋម របស់រដ្ឋបាលខេត្តទាំង២ខាងលើ មានព័ត៌មានជាក់លាក់ មួយចំនួនដែលត្រូវការបន្ថែមទៀត ដូចជាប្រវត្តនៃការបំពេញការងារ ធ្លាប់ទទួលបានប្រាក់សោធននិវត្តន៍ ឬមិនធ្លាប់ទទួលបាន ដើម្បីឲ្យមានភាពគ្រប់ជ្រុងជ្រោយ សម្រាប់ការសិក្សា។

# ៣.៥.ការសិក្សាលើការផ្តល់ប្រាក់សោធននិវត្តន៍ (ត)

➢ បញ្ហាប្រឈម និងកិច្ចការបន្ត

- វិសាលភាពនៃទិន្នន័យមានទំហំធំ និងមានសមាសធាតុព័ត៌មានបុគ្គល មានច្រើន។
- ភាពស្មុគស្មាញនៃការគ្រប់គ្រងទិន្នន័យក្រុមប្រឹក្សា នៃរដ្ឋបាលថ្នាក់ក្រោមជាតិ (ច្រើនឆ្នាំបើគិតតាំងពីអាណត្តិទី១, ក្រុមប្រឹក្សាឃុំសង្កាត់មួយចំនួន បានផ្លាស់ប្តូរទៅក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្ត ខណៈដែលចំនួនអាណត្តិខុសគ្នា ទៅតាមប្រភេទក្រុមប្រឹក្សា, ការផ្លាស់ប្តូរស្ថានភាព (ស្លាប់ ឬប្តូរទីលំនៅ)។
- ទិន្នន័យសមាជិកក្រុមប្រឹក្សា មិនទាន់មានក្នុងប្រព័ន្ធឌីជីថល គ្រប់ជ្រុងជ្រោយនៅឡើយ ខណៈដែលទិន្នន័យមួយចំនួនធំ ស្ថិតក្នុងស្ថានភាពរាយប៉ាយ និងការគ្រប់គ្រងបែបក្រដាសដាច់ដោយឡែកពីគ្នា ពីសំណាក់រដ្ឋបាលរាជធានី-ខេត្ត ទាំង២៥។
- ខ្វះការផ្សព្វផ្សាយអំពីខ្លឹមសារនៃសមាសធាតុទិន្នន័យនីមួយៗ ដែលត្រូវការចាំបាច់សម្រាប់ការងារសិក្សារៀបចំសោធន ជូនក្រុមប្រឹក្សា ជាហេតុបណ្តាលឱ្យ អសង្គតិភាពក្នុងការបំពេញតារាងទិន្នន័យបឋម។

# សូមអរគុណ